# ការសម្ភាសរបស់បងស្រី ដារ៉ូណា

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះដារ៉ូណា

កៈ ជាដំបូងសូមជំរាបសួរបង!!

ខៈ ចាស!ជំរាបសួរអូន!!

កៈ
ចាស!ថ្ងៃនេះខ្ញុំមានឳកាសដើម្បីនឹងសំភាសន៍បងផ្ទាល់ទាក់នឹងពង្សប្រវត្តិប្រជាជានកម្ពុជាហើយខ្ញុំបានស្មាគចិត្តធ្វើការងារនេះជាមួយនឹងសាលាផ្ទាល់ហេតុដូចនេះការងារនេះគឺយើងតំរូវអោយសំភាសន៏របស់គាត់ហើយអាចនឹងរក្សាទុកនូវសំលេងរបស់គាត់ឬរបស់បងនឹងទៅអោយខាងសាលាចឹងហើយយើងនឹងមានការធ្វើបែបនេះហើយអោយយកទៅខាងសាលាអោយគេយកសំលេងដែលបានសំភាសន៏រួចហើយទៅដាក់នៅវេបសាយរបស់សាលាទៅកាន់សារធារណៈជាពិសេសអ្នកដែលគាត់អាចចូលទៅកាន់វេបសាយនឹងហើយពួកគាត់អាចស្តាប់សំលេងរបស់បងស្រីផ្ទាល់ហើយគាត់អាចស្តាប់បានគ្រាប់ពេលវេលានឹងទីកន្លែងបាន។
ដូចនេះខ្ញុំមានឳកាសដើម្បីនឹងធ្វើការសំភាសន៍ទៅកាន់បងស្រីផ្ទាល់ហេតុដូច្នោះហើយតើបងស្រីអនុញ្ញាតដើម្បីអោយខ្ញុំបានសំភាសន៏បងស្រីដែលឬទេ?

ខៈ ចាស!បងអនុញ្ញាតអូន។

កៈ ចាស!អរគុណបងច្រើនណាបង ចឹងជាដំបូងតើបងមានឈ្មោះអ្វីដែល?

ខៈ ចាស!ឈ្មោះរបស់ខ្ញុំមានឈ្មោះថា ចាស ដារ៉ូណា។

កៈ ចាស!ឈ្មោះរបស់បង ត្រូវជាមួយនឹងអត្តសញ្ញាណប័ណ្ណដែលឬទេ?

ខៈ ចាស!អូនត្រូវជាមួយនឹងអត្តសញ្ញាណប័ណ្ណ។

កៈ ចាស!ហើយតើបងមានទីលំនៅកំណើតនៅឯណាដែល?

ខៈ ចាស!ទីលំនៅរបស់បងហែស?

កៈ ចាស!

ខៈ ទីលំនៅរបស់បងនឹងមាននៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

កៈ ចាស! ហើយសព្វថ្ងៃនឹងបងមានទីលំនៅតែមួយឬក៏បងមានការផ្លាស់ប្តូរទីលំនៅ?

ខៈ ចាស!ខ្ញុំមានការផ្លាស់ប្តូរទីលំនៅមកនៅភ្នំពេញណាអូន។

កៈ ចាស!

ខៈ ចាស!ហើយថ្ងៃណាយើងទៅលេងផ្ទះចឹងទៅបានយើងទៅស្រុកនេះបងមកឡធ្វើការនៅទីក្រុងភ្នំពេញទេអូន។

កៈ ចាស!!

ខៈ ចាស!ហើយបងមកធ្វើការធម្មតាទេនៅភ្នំពេញនេះនោះ។

កៈ ចាសចឹងសព្វថ្ងៃនឹងបងមានទីលំនៅនឹងនៅក្នុងភូមិឃុំណាដែលដែលបងបានផ្លាស់ទីលំនៅមកនៅនឹង?

ខៈ នៅទីនេះគេហៅថាបឹងសាឡាន សង្កាត់ឬស្សីកែវ ខណ្ឌ ឬស្សីកែវ។

កៈ ចាស!នៅឬស្សីកែវទីនេះ

ខៈ ចាស!!!

កៈ ចុះបងឥឡូវនឹងពេលដែលបងមកធ្វើការនៅភ្នំពេញនឹងតើបងមានបានដឹងថាពួកគាត់ទាំងអស់គ្នាសុខសប្បាយដែលឬទេបង?

ខៈ ចាស!ពួកគាត់ទាំងអស់គ្នានឹងគឺគាត់សុខសប្បាយទេ។

កៈ ចាស!តើពួកគាត់នៅផ្ទះជុំគ្នាឬនៅបែកគ្នាដែលបង?

ខ៖ គាត់នៅបែកគ្នាទេអូនហើយគ្រួសារបងនឹងមកនៅជុំគ្នា។

ក៖ អូចឹងតើគ្រួសារបងមកនៅជាមួយដែល?

ខ៖ នឹងហើយតែប្អូនបងគេនៅឯស្រុកកំណើត។

ក៖ អូចឹងបងមានគ្រួសារហើយ?

ខ៖ ចាស!អូនបងមានគ្រួសារហើយ។

ក៖ ចឹងតើស្វាមីរបស់បងគាត់មានឈ្មោះអ្វីដែលទៅ?

ខ៖ ចាសគាត់មានឈ្មោះថាលីរដ្ឋា។

ក៖ ចាស ចឹងតើបងមានកូនប៉ុន្មានហើយបងស្រី?

ខ៖ ចាស ខ្ញុំមានកូនចំនួន២នាក់ហើយ។

ក៖ តើគាត់ទាំង២នាក់នឹងពួកគាត់មានឈ្មោះអ្វីខ្លះទៅ?

ខ៖ គាត់មានឈ្មោះ រដ្ឋាភាយុក នឹងរដ្ឋាស្រីមុំ។

ក៖ តើពួកគាត់ទាំងអស់គ្នានឹងបានចូលរៀនដែរឬទេ?

ខ៖ គាតទាំងអស់គ្នានឹងបានចូលរៀនតើអូន។

ក៖ តើពួកគាត់បានចូលរៀនថ្នាក់ទីប៉ុន្មានខ្លះទៅបង?

ខ៖
កូនទី១នឹងបានចូលរៀនថ្នាក់ទី១ម្នាក់ហើយមួយទៀតមិនទាន់បានចូលរៀនទេព្រោះមិនទាន់បានគ្រាប់អាយុ។

ក៖
ចាស!ហើយចឹងបងស្រីនឹងបងប្រុសពេលដែលមុននឹងសំរេចចិត្តរៀបការនឹងតើបងទាំង២នាក់ស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នកដែររៀបចំអោយ?

ខ៖ កាលនឹងបងស្រលាញ់គ្នាទេមិនមែនឪពុកម្ដាយគាត់ជាអ្នកផ្សុំផ្គុំអោយបងនោះទេ។

ក៖ ចាស!ហើយចឹងបងកាលនឹងបងមានរយៈពេលប៉ុន្មាន ឆ្នាំដែរ?

ខ៖ កាលនឹងបានប្រហែលជា១០ឆ្នាំហើយ។

ក៖ ចាស!ចឹងកាលនឹងបងស្រីបានរៀបការជាមួយនឹងបងប្រុសរយៈពេលបាន១០ហើយ?

ខ៖ ចាស!!

ក៖
ហើយចឹងបងស្រីក៏បានរៀបការហើយបង្កើតជាក្រុមគ្រួសារមួយហេតុដូចនេះហើយចឹងតើសព្វថ្ងៃនេះនឹងបងស្រីនឹងបងប្រុសមិនបានលែងគ្នាឬក៏មានបញ្ហាអីទេ?គាត់សព្វថ្ងៃនឹងគឺនៅជាមួយនឹងបងស្រីឯភ្នំពេញ?

ខ៖ ចាសគាត់នៅជាមួយគ្នា។

ក៖ ចាសគាត់បាននៅជាមួយនឹងគ្នា។

ខ៖ ចាស

ក៖ ចឹងទៅសព្វថ្ងៃនឹងតើគាត់មានមុខរបរជាអ្វីដែលបងប្រុសនោះ?

ខ៖
ចាស!គាត់ស៊ីឈ្នួលគេគ្មានបានធ្វើការងារអីធំដុំអីនោះគេបងប្រុសនោះហើយគាត់គ្រាន់តែធ្វើការងារធម្មតានឹងគាត់ទៅស៊ីឈ្នួលគេទេ។

ក៖ ហើយចុះបងស្រីវិញតើសព្វថ្ងៃនឹងតើបងមានមុខរបរជាអ្វីដែល?

ខ៖ បងហ៎
បងនឹងក៏ស៊ីឈ្នួលទៅលាងចានអីអោយគេដែលព្រោះឥឡូវនឹងបងមិនទាន់មានការងារអីធ្វើនោះទេ គ្មានទាន់បានការងារធ្វើទេ។

ក៖ ចឹងឥឡូវនឹងបងនៅមើលផ្ទះ?

ខ៖ ចាសបងនៅចាំផ្ទះនឹងមើលកូនអីចឹងទៅ។

ក៖ ហើយអើចឹងតើសព្វថ្ងៃនឹងបងមានឪពុកម្ដាយដែលគាត់នៅជីវិតរស់នៅដែលឬទេបង?

ខ៖ ចាស!មានតើបងមានឪពុកនឹងម្ដាយដែលគាតនៅមានជីវិតរស់នៅសព្វថ្ងៃនឹងនោះ។

ក៖ ចាស! ចឹងតើពួកគាត់មានឈ្មោះអ្វីខ្លះដែលទៅបង?

ខ៖ ឪពុកបងឈ្មោះ ឈាំ ជាតិ ហើយ ម្ដាយបងវិញគាត់មានឈ្មោះថាកែវ យ៉ាន។

ក៖ ចាស!ហើយពួកគាត់មានទីលំនៅសព្វថ្ងៃនៅឯណាដែរ?

ខ៖ នឹងគាត់មានទីលំនៅសព្វថ្ងៃនឹងនៅឯស្រុកឯនោះ នៅខេត្តត្បូងឃ្មុំ។

(ឆ្កែកំពុងតែព្រួសៗ)

ក៖ ចាស!ចឹងតើសព្វថ្ងៃនឹងបងមានបងនឹងប្អូនប៉ុន្មាននាក់ដែរបង?

ខ៖ ចាស! សព្វថ្ងៃនឹងបងមាន៥នាក់។

ក៖ តើពួកគាត់មានឈ្មោះអ្វីខ្លះដែរ?

ខ៖ គាត់មានឈ្មោះថា ឡាង ឈ័ន សីហា សុខឃីម ។

ក៖
ចាស!ហើយបពួកគាត់ទាំងអស់គ្នាបានរៀបអាពាហ៍ពិពាហ៍ទាំងអស់គ្នាឬក៏ពួកគាត់នៅលីវ?

ខ៖ ចាស!ពួកគាត់បានរៀបអស់ហើយ
នៅតែកូនម្នាក់ដែលមិនទាន់បានរៀបហើយចំណែកឯកូនផ្សេងទៀតនឹងពួកគេបានរៀបការអស់ហើយអូន។

ក៖ អឺ!! ចាស!ចឹងពេលដែលគាត់បានរៀបការហើយនឹងពួកគាត់បានទៅរស់នៅផ្សេងៗពីគ្នា?

ខ៖ ចាស!ពួកគាត់បានទៅរស់នៅផ្សេងៗពីគ្នា។

ក៖ ចាស! ចឹងតើបងបានដឹងទេថាពួកគាត់មានទៅលំនៅឯណាខ្លះទៅនៅភូមិឃុំណាដែល?

ខ៖ បងមិនបានស្គាល់នោះទេ។

ក៖ ចឹង!ហ៎ចឹងតើបងមានបានសួរពួកគាត់ដែលឬទេ?

ខ៖ ដឹងថាគាត់មួយនោះនៅស្រុកអញ្ចាញមានឹងនៅក្នុងខេត្តព្រៃវែង ។

ក៖ ចាសចឹងបងមានបានទៅលេងគាត់ដែរ?

ខ៖ បានទៅតើតែបងមិនបានដឹងថាភូមិឃុំគេនឹងឈ្មោះអីទេ។

ក៖ ចាស!! ហើយចឹងពួកគាត់ទាំងអស់គ្នាដែលបានរៀបការហើយនឹងមានកូនអស់ហើយ?

ខ៖ មានកូនអស់ហើយ

ក៖ ចាស!ចឹងតើគាត់រកស៊ីអីដែលនៅឯនឹង?

ខ៖ គាត់រកស៊ីលក់ឥវ៉ាន់ចាបហួយ

ក៖
ចាស!ហើយតើបងប្អូនរបស់បងផ្ទាល់នឹងមានអ្នកណាដែលបានស្លាប់នៅក្នុងជំនាន់អាពតដែលឬទេបង?

ខ៖ អត់មានទេ។

ក៖ ចាស!អត់មានទេន៎
ចាសហើយលោកតានឹងលោកយាយដែលត្រូវជាលោកតានឹងលោកយាយបង្កើតរបស់លោកយាយនឹងតើគាត់សព្វថ្ងៃនឹងពួកគាត់មានអាយុប៉ុន្មានឆ្នាំដែល?

ខ៖ អត់បានចាំទេ។

ក៖ ចាស!ចុះឈ្មោះរបស់ពួកគាត់វិញតើគាត់មានឈ្មោះអ្វីដែល?

ខ៖ ពួកគាត់ជាលោកតានឹងយាយបងនឹងន៎គាត់មានឈ្មោះថាតាម៉ីនឹងយាយយ៉ាន។

គាត់ឈ្មោះថាតាម៉ីនឹងយាយយ៉ានចឹងហើយ។

កៈ ចាស!!!

ខៈ ចាសប៉ុន្តែខ្ញុំមិនបានដឹងថាគាត់មានប្រជ័ន្មប៉ុន្មាននោះទេ។

កៈ ចាស!ចឹងពួកគាត់មានព្រះជន្មវែងណាស់ន៎បង?

ខៈ ចាស!ប៉ុន្តែពួកគាត់បានស្លាប់បាត់អស់ហើយនឹង។

កៈ តើពួកគាត់យូរនៅបង?

ខៈ គាត់បានស្លាប់យូរហើយតាំងពីបងនៅពីក្មេងៗម៉េចនេងហើយអូន។

កៈ ចាស!បងចឹងយូរណាស់ដែលហើយនឹង។

ខៈ នឹងហើយអូនចាសវាដូចជាយូរណាស់ហើយនឹងអូន។

កៈ ចឹងបងបាននឹកគាត់ហើយចឹង។

ខៈ បងនឹងគាត់តើអូន។

កៈ
ចាស!ហើយកាលនឹងនោះបងមានអាយុនៅក្មេងៗដែលចឹងតើបងបានដឹងទេថាកាលនឹងតើគាត់បានស្លាប់ដោយសារអ្វីដែរទៅបង?

ខៈ
គាត់ស្លាប់ដោយសារជំងឺស្លាប់មួយចំហាងខ្លួននឹងណាអូនដើយគាត់អត់មានបានឈឺនោះទេគាត់បានស្លាប់មួយចំហៀងខ្លួនតែម្តងនឹងអូនអើយ។

កៈ ចាសៗនឹង២នាក់តែម្តងនឹងមែនបង? តាំងលោកតានឹងលោកយាយមែនបង?

ខៈ
តែលោកតាទេអូនតែលោកយាយនឹងបងមិនបានដឹងទេអូនអើយ។កាលនឹងបងមិនបានទាន់លោកយាយនោះទេកាលនឹងបងបានទាន់តែលោកតាស្លាប់នោះតែម្តងនឹងអូនអើយ។

កៈ
ហើយចំពោះបងនឹងក្រុមគ្រួសារតើបងមានផែនការសំរាប់ទៅធ្វើការងារនៅកន្លែងផ្សេងដែលឬទេ?បងមានដែលឬទេសំរាប់គំរោងការណ៍អាគតរបស់ផ្ទាល់?

ខៈ បងហ៎អូន?

កៈ ចាស!!

ខៈ បងចង់ធ្វើការងារនៅភ្នំពេញនឹងតែម្តហានឹងអូនអើយ
ហើយបងចង់អោយខាងសាលារៀននៅBYUនឹងបានជួយដល់ខាងសាលារៀននៅស្រុកខ្មែរយើងផងព្រោះវាឥឡូវនឹងវាដូចជាយ៉ាបណាស់កាន់តែយ៉ាបៗទៅហើយអូនអើយបងចង់តែធ្វើការនៅនឹងភ្នំពេញនឹងទេ
បងមិនចង់ទៅធ្វើការងារនៅតាមខេត្តនោះទេអូនអើយបងនឹងគ្រួសារបានមកនឹងដោយសារតែមូលហេតុនឹងហើយបានជាបងសំរាចចិត្តនឹងដើម្បីអោយបានការងារនៅភ្នំពេញយើងនឹងតែដឹងអីបើឥឡូវនឹងវាមិនទាន់បានការងារធ្វើផងនឹងហើយបងនឹងចង់អោយសាលានឹងជួយបងនឹងប្រជាជននៅក្នុងស្រុកខ្មែរផងព្រោះវាកាន់តែយ៉ាប់ណាស់ទោហើយនឹង។

កៈ ចាស!! ហើយបងបានសិក្សានៅកំរិតណាដែលបង?

ខៈ បងបានរៀនត្រឹមថ្នាក់ទី៧
ព្រោះតែម្តាយឪពុកនឹងគាត់ក្រពេកចឹងហើយបានជាពួកគាត់អោយបានរៀនត្រឹមថ្នាក់កំរិតតិចចឹងនោះ។ហើយក៏ព្រោះមួយទៀតនឹងដោយសារតែបងនឹងវាពិបាកនៅជាមួយនឹងគេព្រោះកាលនឹងម៉ាក់នឹងបានយកបងនឹងទៅភ្ញើរជាមួយនឹងគេនឹងអូនអើយចឹងហើយបានថាបងនឹងវាពិបាកធ្វើការសិក្សាបានល្អណាស់ចឹងហើយបានជាបងនឹងម៉ាក់នឹងអោយឈប់ការសិក្សានៅត្រឹមថ្នាក់ទី៥ចឹងម៉ង់ទៅព្រោះកាលនឹងនៅជាមួយនឹងគេវាមិនល្អដូចជានៅនឹងជាមួយនឹងម្តាយឪពុករបស់ខ្លួនឯងនោះទេណាអូនណា។ហើយបងនឹងថាមនឹងចង់ជួលសន្សំលុយម៉ែឪពុកនៅស្រុកអោយគាត់បានធូខ្លះនឹងហើយចឹងទៅបានជាខ្ញុំនឹងឈប់រៀនទៅម្តងទៅ។

កៈ កាលនឹងបងមានបំណាងប្រាថ្នាចង់ធ្វើអ្វីដែល?

ខ៖ កាលនឹងនោះបងមិនបានដឹងថាបងចង់ធ្វើអីនោះទេស្អីក៏គ្មានៗ
ពេលខ្លះទៅបងនឹងបានទៅស៊ីឈ្នួលគេប៉េះសណ្តែកចឹងទៅអោយគេចឹងទៅហើយកាលនឹងបងបានទៅស៊ីឈ្នួលអោយគេហើយចឹងទៅបងដឹងថាវានឹងពិបាកពេលដែលបងនឹងបានទៅស្រុកលើនឹងចឹងបានជាបងនឹងសុខចិត្តប្តូរមកធ្វើការងារនឹងនៅភ្នំពេញនឹងវិញនោះព្រោះតែកាលនៅឯស្រុកលើនឹងបងវាពិបាកពេកទាំងការស្នាក់នៅ
ទាំងទឹកនឹងការហូបចុចអីនឹងវាមិនបានស្រួលដូចជានៅទីនេះនោះទេយើងបានខ្វាចច្រើនណាស់ដូចជាទីមួយនឹងយើងខ្លាចពស់ យើងខ្លាចឥន្ទ: យើងខ្លាចភាពងងឹត។
ហើយនិយាយមួយទៀតនឹងគឺដោយសារតែនៅទីនេះណាវាបានភ្លឺហើយចឹងទៅបានជាបងថាបើលើសខ្វះគ្នាអីតិចតួចអីនឹងបងយកហើយព្រោះវាពិបាកចិត្តថាបើនៅទីនេះនឹងបានស្រួលហើយតែអត់មានការងារធ្វើនោះពិតជាយ៉ាបជាមិនខាននោះទេព្រោះអត់មានលុយដើម្បីអោយទៅគេនឹងណាអូន។ចឹងហើយបានជាបងនឹងបានមកនៅទីនេះទៅវាស្រួលជាងចឹងណាអូន
។

ក៖
ចាស!ចឹងកាលនឹងបងបានទៅនៅស្រុកណាដែលការដែលបងបានធ្វើការងារចាស់នៅឯស្រុកលើនោះណាបង?

ខ៖
កាលនឹងនោះបងបានទៅស៊ីឈ្នួលគេហើយក្នុង១ខែបងនឹងបានតែ២០ទេកាលនឹងនោះហើយពេលនឹងបងនឹងថាបងនឹងបានស៊ីឈ្នួលគេនៅក្នុងកណ្តាលក្រុងតែម្តងនឹងហើយកាលនឹងណាបងបានទៅធ្វើនឹងការរៀបចំបន្ទប់អីសំរាប់ភ្ញៀវអីចឹងទៅណាអូន។

ក៖ ចាសចឹងកាលនឹងបងបានធ្វើអ្វីខ្លះទៅបងកាលនឹងនោះ?

ខ៖
កាលនឹងបងបានជួយគេរៀបចំបន្ទប់អីនឹងនៅក្នុងកន្លែងគេនឹងហើយអូនអើយបងវាពិបាកណាស់ដែលនឹងកាលនឹងព្រោះវាហាត់។

ក៖
ចាស!ហើយបងចឹងកាលនឹងពេលដែលមុននឹងទៀតតើបងបានធ្វើអ្វីខ្លះដែលនៅឯស្រុកលើកន្លែងដែលបងបានទៅស៊ីឈ្នួលគេនៅឯស្រុកលើនឹងនោះបង?

ខ៖
អូ!!!កាលនឹងឯស្រុកលើនឹងបងបានធ្វើការងារច្រើនដែលតើដូចជាកាលនឹងបងស៊ីឈ្នួលគេនឹងបងទៅយូរដែលហើយអូនអើយកាលនឹងនោះបងមិនបាននឹងទៅន្លែងផ្សេងក្រៅពីស្រុកលើនឹងទេកាលនឹងនោះជូនកាលនៅពេលនឹងបងមានការងារខ្លះនឹងគឺគេអោយបងនឹងកូសដំឡូងនឹងនៅក្នុងចំការគេតែម្តងនឹងអូនអើយហើយគេគិតអោយយើងនឹងក្នុង១កញ្ចែកអីនឹងបាន៣០០រទេអូនអើយ១០
កញ្ចែងអីនឹងមិនបានដល់៥០កញ្ចែងអីនឹងផងនៅក្នុង១ថ្ងៃនោះអីអូនអីវាពិបាកណាស់កាលនឹងនោះហើយនិយាយពីការងារនៅឯស្រុកលើនឹងបងបានស៊ីឈ្នួលគេនឹងនៅឯស្រុកចំការលើនោះឯណោះចឹងហើយបានជាបងនឹងចង់មកធ្វើការនៅនឹងភ្នំពេញវិញ។ហើយកាលដែលបងមានបាននឹងមកនឹងបងដឹងថាកាលនឹងបងបាធ្វើការនៅស្រុកលើនឹងវាមិនបានច្រើនប៉ុន្មាននោះទេហើយបងបានដឹងថាកាលនឹងវានៅក្នុងខេត្តកំពង់ចាមហើយឥឡូវនឹងវាស្ថិតនៅក្នុងខេត្តត្បូងឃ្មុំវិញុំ

ក៖ ចុះកាលនឹងបងបានធ្វើអ្វីខ្លះកាលនឹងនោះ?

ខ៖
អូ!!!កាលនឹងបងមិនមានបានត្រឹមតែកូសដំឡូងនឹងទេតែបងមានការកាប់វាដែលបន្ទាប់ពីបងកូសហើយនឹងនោះបងក៏ត្រូវកូសខ្លួនឯងហើយកាប់ខ្លួនឯងដែលនឹងហើយបើថាបងចង់អោយគេធ្វើក៏បានដែលបងគ្រាន់តែយកកូសអោយគេហើយបងនឹងក៏គ្រាន់តែសំរាប់កូសហើយបោះអោយគេទៅបានហើយ។

ក៖ គេកូសធ្វើអ្វីដែលបង?

ខ៖ គេកូសហើយគេបានចញ្ចាំហើយទៅសំរាប់យកទៅដាក់ហាល
ហើយពេលដែលគេកូសហើយនឹងគេបានកាប់វាដើម្បីយកវាទៅហាលថ្ងៃអីចង់ទៅសំរាប់យក

ទៅលក់បន្តសំរាប់ចូលទៅក្នុងរោងចក្រអីចឹងទៅហើយគេនឹងទៅធ្វើជាមីឬម្សៅអីផ្សេងៗចឹងទៅណា។ហើយយើងនឹងគ្រាន់តែស៊ីឈ្នួលអោយគេចឹងទៅ។

កៈ ហើយយើងនឹងគ្រាន់តែស៊ីឈ្នួលអោយគេទេ?

ខៈ
ចាសយើងនឹងគ្រាន់តែស៊ីឈ្នួលទៅអោយគេនឹងបានហើយយើងមិនទៅបានដឹងនឹងធ្វើច្រើនជាងនេះនោះទេអូនអើយ។

កៈ ហើយកាលនឹងបងអាចរកប្រាក់ចំណូលបានប៉ុន្មាននៅក្នុង១ល្អី?

ខៈ បើគិតទៅបងកាលនឹងរកប្រាក់នឹងតាមរយៈស៊ីប្រាក់តាមចំនួនល្អីនឹងទេអូន។

កៈ
ចាសបងបានរកនឹងតាមរយៈស៊ីជាចំនួនល្អីចឹងចាសចឹងក្នុង១ល្អីចឹងអាចធ្វើបានប៉ុន្មានល្អីដែរ?

ខៈ វាមិនទៀងទេអូនអើយ។

កៈ ចុះចឹងក្នុងមួយល្អីនឹងគេមានអោយបង១ល្អី៣០០រ?

ខៈ ចាសក្នុង១ល្អីគេបានអោយបងនឹងបាន៣០០រដែរនឹង។

កៈ ចាសចឹងនៅក្នុង១ថ្ងៃតើបងអាចរកប្រាប់បានប៉ុន្មានហើយបានប៉ុន្មានល្អីដែរបង?

ខៈ បងអាចរកបាន៨ល្អីអីម្នាក់ឯងនឹង។

កៈ
ចាសចឹងកាលនឹងបងមានគ្រួសារហើយនៅកាលនឹង?មានន័យថាកាលនឹងនោះបងមានបានរៀបអាពាហ៍ពីពាហ៍ហើយឬនៅកាលនឹងនោះ?

ខៈ
កាលនឹងបងបានមានគ្រួសារហើយៗកាលនឹងនោះពេលនឹងបងបានមានបានរស់នៅជាមួយនឹងឪពុកម្តាយដែលពួកគាត់នឹងបានអោយបានយើងនៅជាមួយនឹងគាត់ទោះបីជាពេលនឹងគា

ត់នៅមានជីវៈភាពលំបាកហើយខ្វះខាតនឹងអត់មានក៏គាត់នៅតែអោយយើងនៅជាមួយនឹងគាត់ដែល។

កៈ
ចាសចុះដល់ពេលដែលបងបានទៅនឹងតើបងបានជួបកាលលំបាកអីគេខ្លះដែលបងកាលនឹងនោះ?

ខៈ ចាស

កៈ
ចាសកាលនឹងតើបងនឹងបានជួបកាលលំបាកអីគេខ្លះកាលនឹងពេលដែលបងបានទៅធ្វើការងារនៅឯស្រុកលើនឹងនោះ?

ខៈ
អូកាលនឹងបងបានជួបការលំបាកនឹងគឺមានមេឃនឹងវាភ្លៀវវាលំបាកនៅណាស់កាលនឹងនោះពេលដែលមានមេឃភ្លៀងមកម្តងៗនឹងនោះ
ហើយបងនឹងនៅស្រុកគេនឹងបងខ្លាចមេឃភ្លៀងនឹងរន្ទះនឹងណាអូនបងខ្លាចណាស់បងមិនដឹងធ្វើម៉េចទេអូនកាលនឹងពេលដែលមានមេឃភ្លៀងមកម្តងៗនឹងនោះ
ហើយមួយទៀតនឹងបងបានចាំថាកាលនឹងបងមានអារម្មណ៍អាកាសធាតុនៅស្រុកលើនឹងវាក្តៅខ្លាំងណាស់ព្រោះអូនឯងគិតមើលនៅនឹងគ្មានដើមឈើអីណាអូនមានតែគេដាំដំណាំនឹងនៅចំការជំឡូងគេនឹងចឹងមើលទៅវាក្តៅខ្លាំងណាស់អូនអើយ។

កៈ ចឹងកាលនឹងគេមិនមានតែចំការទេនៅកន្លែងដែលបងស្នាក់នៅនឹង?

ខៈ
ចឹងហើយអូនកាលនឹងបងនៅក្នុងតង់គេនឹងហើយគេបោះតង់នៅក្នុងចំការនឹងម៉ងនឹងហើយនឹងអូនអើយ។

កៈ
ចាសចឹងកាលនឹងបងបានផ្លាស់ប្តូរការងារនៅឯភ្នំពេញនឹងវិញហើយចឹងកាលនឹងតើបងមានបានប្រាថ្នាអីផ្សេងទេពេលដែលបងបានទៅធ្វើការងារខាងឯកូសដំឡូងនឹងនោះ?តើបងមាន

បានប្រាថ្នាថានឹងធ្វើការងារអ្វីផ្សេងទេពេលដែលបងកំពុងតែជួបកាលលំបាកពេលដែលបងនៅស្រុកចំការលើនៅក្នុងចំការដំឡូងមីនឹង?

ក៖ បងហាំ?

ខ៖ ចាសបង!!

ក៖
បងវិញនឹងកាលនឹងបងគិតថាធ្វើអ្វីនឹងវាធ្វើមិនដល់ឬមិនបាននោះទេចឹងហើយបានជាបងថាបងចង់ធ្វើការងារអ្វីដែលជួយបាននឹងអាចនៅក្នុងផ្ទះបានដូចជាការលក់ដូរហើយការលក់ដូរនឹងបងគិតថាមានតែការលក់ដូរដូចជាលក់ឥវ៉ាន់ចាបហួយអីនឹងដែលអាចជួយដល់បងបានណាអូន។
យើងអាចនៅផ្ទះផងហើយយើងនឹងអាចមើលថែរក្សារកូននៅផ្ទះបានទៀតណាអូនណាចឹងហើយបានជាបងនឹងចង់ធ្វើការងារនឹងនោះហើយវាធ្វើអោយបានដឹងថាវានឹងអាចអោយបងបានស្រួលជាងមុខជាមួយនឹងមុខរបរនឹងអាអូនចឹងហើយបំណងប្រាថ្នារបស់បងនឹងគឺជាការលក់ដូរអាឥវ៉ាន់ចាហួយបន្តិចបន្តួចនឹងនៅក្នុងផ្ទះនឹងតែប៉ុន្នឹងដែរនឹងបងអត់មានអីច្រើនទេសំរាប់អ្វីការងារមួយនឹងនោះ។ហើយបងមានចិត្តចង់មើលកូននៅផ្ទះនឹងព្រោះបងនឹងក៏បានគិតថាបងនឹងជាមនុស្សស្រីនឹងចឹងបងចង់អោយនឹងថាបងមានក្តីប្រាថ្នាបងនឹងចឹងឯង។

ក៖
ចាស!បងបងគិតចឹងត្រូវហើយតែបងពេលដែលបងបានទៅធ្វើការងារនៅឯស្រុកលើនឹងតើបងទៅធ្វើការងារនៅនឹងតាមរយៈអ្នកណាគេដែលបង?

ខ៖ កាលនឹងបងបានទៅធ្វើការងារនឹងតាមរយៈ បងប្អូនខ្លួនឯងនឹងអាប្អូនអើយវាចឹងឯង។

ក៖ អូ!!!ចឹងកាលនឹងគេបានប្រាប់បងថាយ៉ាងម៉េចខ្លះដែលទៅ?

ខ៖
ចាស!!កាលនឹងនោះបងនឹងបានដឹងថាគាត់នឹងមកប្រាប់ថានៅឯស្រុកលើនឹងគេមានការរើសសំរាប់អ្នកដែលអាចទៅធ្វើការងារអោយគេបាននៅឯស្រុកលើនឹងការងារនឹងគេអោយយើងនឹងធ្វើជាអ្នកកូសដំឡូងនឹងអ្នកដែលកាប់ដំឡូងសំរាប់អោយគេយកទៅធ្វើបន្តទៀតដើម្បីយកចូ

លទៅក្នុងឯរោងចក្រណាអាអូនចឹងឯង។
គេបាននាំយើងទៅកាលនឹងនោះគឺគេបាននាំយើងដោយគេបានដាក់យើងនឹងក្នុង១ឡានទៅកាលនឹងនោះ។

ក៖ អូ!!!នឹងចឹងកាលនឹងបងបានទៅនឹងមានគ្នាទៅជាមួយដែលត្រូវអត់បង?

ខ៖ នឹងហើយអូនកាលនឹងបងទៅនឹងបងបានទៅជាមួយអ្នកភូមិខ្លួនឯងឡើង១ឡានឯនោះ។ យើងមិនមិនបានទៅម្នាក់ឯងនោះទេ។

ក៖ ចាសចឹងកាលនឹងបងបានទៅជាមួយនឹងអ្នកភូមិខ្លួនឯង?

ខ៖ អឺនឹងហើយអូន។

ក៖ ចឹងកាលនឹងបងបានស្នាក់នៅឯណាដែរ?

ខ៖ កាលនឹងបងបានទៅស្នាក់នៅក្នុងព្រៃនឹងណាអូនអើយ។

ក៖ ចាស!ចឹងបងទៅនៅឯក្នុងព្រៃ?

ខ៖
នឹងហើយប្អូនអើយកាលនឹងនោះបងនឹងចេះតែទៅហើយបើគេអ្នកខ្លាចនោះគេមិនទៅហ៊ានទៅនោះទេកាលនឹងវានៅក្នុងព្រៃហើយវាគួរអោយខ្លាចណាស់កាលនឹងនោះបើគេមិនហ៊ាននោះទៅនៅមិននឹងនៅតែកាលនោះ។

ក៖ ចាស!ចឹងកាលនឹងបងហ៊ានទៅដែលចឹងនោះ?

ខ៖ ចាស!
កាលនឹងបងហ៊ានទៅព្រោះបងនឹងវាទាល់ហើយនឹងចឹងហើយបានជាបងនឹងត្រូវតែទៅដើម្បីបានការងារធ្វើនឹងរកលុយបានយកមកអោយម្ដាយនៅឯផ្ទះនឹងចឹងណាអូនហើយកាលនឹងណាគេអោយបងនឹងទៅគេងនឹងមិនមែនមានតែម្នាក់ឯងនោះទេកាលនឹងនោះបងបានទៅជាមួយនឹងគ្នាមានប្រុសមានស្រីអីចឹងទៅចឹងហើយបងមិនសូវជាខ្លាចនោះទេព្រោះយើងនៅក្នុងតង់នឹងតែយើងមានតង់នៅជិតៗគ្នានឹងណាអូនចឹងយើងអាចជួយគ្នាបានហើយកាលនឹងមានអ្នកដែលទៅនឹងគេនឹងសុទ្ធតែជាអ្នកភូមិរបស់បងនោះទេអូនអើយ

ហើយពេលនឹងបងនឹងបានចាំថាកាលនឹងបងបានងើបដាំបាយនឹងតាំងពីម៉ោង៤ព្រឹកនឹងហើយកាលនឹងណាបងបានងើបមកដើម្បីដាំបាយនៅម៉ោង៤នឹងវាមិនទាន់តែភ្លឺនោះផងនឹង ហើយដល់ពេលដែលកូសហើយនឹងបងបានទៅដកដំឡូងនឹងប្រលែសវាដើម្បីនឹងទុកសំរាប់ថ្ងៃស្អែក
ហើយពេលនឹងដល់ល្ងាចឡើងនឹងបងនឹងចាប់ផ្តើមវែលវាណានៅពេលល្ងាចនឹងប្រហែលជានៅម៉ោងប្រហែលជា៤ទៅម៉ោង៥នឹងបងបានបកសំរាប់ទុកវាដាក់ហាលហើយ ដល់ពេលហើយអីហើយនឹងបងបានមកកញ្ចាំវិញមករហូតដល់អស់ទៅ។

កៈ
ចឹងពេលដែលបងបានធ្វើការងារបងហើយៗតើបងមានការលំបាកអ្វីគេខ្លះទាំងការដេកនឹងការរស់នៅក៏ដូចជាការធ្វើម្ហូបអាហារជាដើមនឹងហើយសំរាប់ការទទួលបានប្រាក់ខែអីនឹងតើបងទទួលបានការលំបាកអីគេខ្លះដែល?

ខៈ ថាម៉េចអូន?

កៈ
ចាសបងខ្ញុំចង់សួរបងថាតើបងមានការលំបាកអីគេខ្លះពេលដែលបងបានចូលទៅធ្វើការនៅឯស្រុកលើនឹង?

ខៈ
អូ!!!អូនកាលនឹងបងបានចូលទៅធ្វើការនៅឯស្រុកលើនឹងបងបានទទួលការលំបាកដូចជាការពិបាកញ៉ាំនឹងការរស់នៅហើយការហូបចុកអីចឹងណាអូនពេលដែលបងបានទៅរស់នៅឯស្រុកលើនឹងនោះគឺបងចាំកាលនឹងនោះបងបានទៅផ្សារដើម្បីទៅទិញត្រីអីសំរាប់ធ្វើម្ហូបអីចឹងណាអូនណាចឹងហើយវាពិបាកព្រោះផ្សារនឹងវានៅឆ្ងាយហើយទៅដល់ចឹងបងត្រូវធ្វើការសន្សំសំរាប់ដាក់ដាំសម្លអីនឹងសំរាប់ទុកដល់ល្ងាចនឹងណាអូន
ហើយសំរាប់បន្លែវិញបងមិនបាច់លំបាកទៅរកនោះទៅបងអាចរកបាននៅជិតៗនឹងព្រោះនៅជិតៗនឹងមានដូចជាជំឡូវ
បន្លែស្លឹកបាសនឹងផ្លីអីចឹងទៅយើងអាចរកវាបាននៅជិតៗនឹងនោះទេហើយពេលដែលបងចង់ស្លចឹងបងបានដឹងថានឹងស្រួលសំរាប់បន្លែចឹងហើយចឹងហើយពេលខ្លះចឹងហើយបានជាបងនឹ

ងទៅផ្សារម្ដងៗនឹង
បងប្រាប់ទៅពេលដែលបងទៅផ្សារម្ដងៗនឹងបងទិញតែសាច់សំរាប់តែសម្លតែប៉ុណ្ណោះអីចឹងទេ។

ក៖ អឺ!!!

ខ៖
អានឹងស្រុកលើកាលនឹងនោះវាចឹងហើយកាលនឹងមានថៅកែលគេនឹងបានទៅផ្សារអីដែលចឹងហើយពេលដែលគាត់នឹងចិត្តល្អទៅគាត់បានជួយទៅកាប់ដំឡូងនឹងអោយដំឡូងនឹងសំរាប់យើងដែលចឹងទៅហើយពេលខ្លះថៅកែលយើងនឹងគាត់បានជួយទិញត្រីអន្លែងអោយចឹងទៅគាត់ក៏បានជួយចែករំលែកអោយគ្នាចឹងដែរទៅ។

ក៖ ចាសចឹងកាលនឹងលោកបានចាំមុខម្ហូបអ្វីសំរាប់បរិភាគ?

ខ៖
កាលនឹងបងមានសម្លម្ជូរទ្រព្យញងអីចឹងទៅហើយពេលខ្លះចឹងទៅបងបានធ្វើជាស្លសំលក់ចឹងទៅដែរនឹងណាអូន។

ក៖
ចុះកាលនឹងបងចូលចិត្តសម្លអ្វីជាងគេដែលបងបានញុំាទៅគឺឆ្ងាញ់ចឹងណា?ដែលបងចូលចិត្តហើយចាំរស់ជាតិនឹងដល់ឥឡូវកាលដែលបងបានស្លញុំាំនៅឯស្រុកលើនឹងនោះ?

ខ៖ អូកាលនឹងបងមានសម្លមួយគឺសម្លសំលក់ផ្លែចេក។

ក៖ សម្លអ្វីគេបង?

ខ៖ សម្លសម្លសំលក់ផ្លែចេក។

ក៖ តើបងបានយកចេកនឹងពីណាមក?

ខ៖ បងបានទៅបេះនៅជិតៗនឹងគឺតាមចំការគេនឹងណាអូន
ពីគ្រសក់យើងនឹងហើយសម្លជាមួយនឹងផ្លែអាណូងយើងដែលចឹងទៅ
ពេលដែលយើងសម្លដាក់លាយគ្នាចឹងទៅវាឡើងឆ្ងាញ់។

កៈ
ចាសទំនងណាស់បងចុះបងចំណែកឯគ្រឿងផ្សំវិញនោះតើបងទៅរកនៅឯណាដែលកាលនឹងឬទិញពីផ្សារមក?

ខៈ
អត់ទេអូនគ្រឿនផ្សំនឹងវាមានអីទៅពិបាកនោះ។យើងដាំតែទឹកអោយតែវាពុះទៅហើយបន្ទាប់មកយើងលាងស្លឹកក្រៃយើងអោយស្អាតហើយបង់ចូលបន្ទាប់មកយើងយកប្រហុកនឹងមកជ្រុំវាទៅដាក់ត្រីឆ្អើរទៅហើយដាក់ផ្លែចេកទៅដាក់ផ្លែគ្រឿងទៅបានហើយ
មានអីទៅពិបាកយើងមិនបាច់ទៅរកនៅផ្សារក៏បានដែលយើងធ្វើខ្លួនឯងនឹងព្រោះវាស្រួលធ្វើទេ។

កៈ ចាស!ចឹងសម្លនឹងបងចូលចិត្តជាងគេ?

ខៈ នឹង!ហើយសម្លនឹងបងចូលចិត្តជាងគេព្រោះបងបានសម្លទៅវាមានរស់ជាតិឆ្ងាញ់។

កៈ ចុះគ្រឿងអីចឹងបងទៅយកពីណាមក?

ខៈ មកបានយកពីចំការទៅនៅជិតៗនឹង។

កៈ ចាសហើយចុះចំណែកត្រីវិញមាននៅជិតៗនោះដែលឬបងបានទៅទិញគេនៅឯផ្សារ?

ខៈ អូត្រីអីចឹងបងបានផ្ញើរគេអោយជួយទិញអោយនៅឯផ្សារ។

កៈ
អូចាសចឹងបងបានវាមកពីការទិញនៅឯផ្សារហើយកាលនឹងបងទៅឯស្រុកចំការលើនឹងតើបងមានបានចាំទេថាបងនៅក្នុងភូមិណាដែល?

ខៈ អូភូមិនឹងបងបានភ្លេចបាត់ទៅហើយ ....

កៈ អូ!!!

ខ៖
ដូចជានៅក្នុងភូមិដាចឹងហើយនេះវាមិនចាំបានច្បាស់ទេកាលនឹងបងដូចជាបានភ្លេចបាត់ទៅហើយឈ្មោះភូមិនឹងនោះ។

ក៖ ហើយកន្លែងដែលបងនៅនឹងគេមានធ្វើជាប្រពន្ធ័ទឹកនឹងនៅកន្លែងនោះដែរមែនដែរឬទេ?

ខ៖
តែធម្មតាកន្លែងដែលយើងរស់នៅនឹងវាតែងតែមានទឹកហើយប៉ុន្តែគ្រាន់តែកន្លែងយើងនៅនឹងវាមានទឹកដែលប៉ុន្តែវាមានទឹកតិចតួចចឹងទៅណាគេជំរូវអោយយើងនឹងត្រូវតែប្រើវាដោយសន្សំសច្ចៃនឹងណាអូនវាប្រើមិនបានច្រើននោះទេទឹកនៅកន្លែងនឹងនោះព្រោះតែយើងដឹងហើយថាទឹកនឹងនៅទីនោះជាកន្លែងដែលដីវាវាងខ្ពស់ចឹងគ្មានទន្លេឬក៏បឹងអីទេគ្រាន់តែមានជាប្រពន្ធ័ទឹកដូចដែលអូនឯបានសួរបងចឹងដណាវាចឹងឯង
ហើយអាអូនអើយកាលនឹងប្រពន្ធ័ទឹកនឹងគេប្រើច្រើនពេកហើយត្រូវបង់លុយអោយគេចឹងហើយមេបងនឹងគេអោយយើងនឹងត្រូវទៅដងទឹកនៅឯអណ្តូងវិញហើយអណ្តូងនឹងមានមនុស្សដងច្រើនពេកចឹងហើយបានជាវារាងរីងទឹកមិនសុទ្ធសំបូរទេវាពិបាកណាស់អូនអើយព្រោះដងទឹកណាស់ទំរាំតែបានក្នុងធុងៗនោះ។

ក៖ កាលនឹងអណ្តូងនឹងគេប្រភេទអណ្តូងដៃឬជាអណ្តូងស្នប់?

ខ៖ វាជាអណ្តូងដែលគេដងដៃ
ហើយគេយកប៉ោតទៅដងយកទឹកនឹងហើយគេធ្វើវាដោយការជីកយកដីចេញមកខាងលើដោយដៃនឹងណាអូន។

ក៖ អូ!!!អានឹងគេបានហៅវាថាជាប្រភេទអណ្តូងខ្មោះ។

ខ៖ ហាស?

ក៖ អណ្តូងខ្មោះ។

ខ៖ ខាងបងនឹងគេហៅថាអណ្តូងដៃវិញ។

ក៖ ព្រោះគេឃើញថាត្រូវយួលដៃឡើងមែនទេបង?

ខ៖ នឹងហើយហាហា...

ក៖ ហើយចឹងកាលនឹងទឹកនឹងវាគ្រាប់គ្រាន់ដែលឬទេកាលនឹងដល់ពេលចឹង?

ខ៖ វាមិនបានគ្រាប់ទេអូនអើយ។

ក៖
ហឹហើយចឹងបងធ្វើយ៉ាងម៉េចដែលទៅព្រោះការបោះតង់នឹងវាក្ដៅខ្លាំងហើយមួយទៀតយើងអត់សូវមានទឹកទៀតចឹងតើបងគិតធ្វើយ៉ាងម៉េចដែល?
ហើយពេលដែលអាកាសធាតុក្ដៅម្ដងៗនឹងបងមានវិធីសាស្រ្ដយ៉ាងម៉េចដែលសំរាប់ជួយបងសំរបជាមួយនឹងវា?

ខ៖ បងមិនដឹងធ្វើយ៉ាងម៉េចទេកាលនឹងនោះបងមានតែទ្រាំតែប៉ុណ្ណោះ....

ក៖ អត់មានដូចថាធ្វើអ្វីទេ?

ខ៖
អូនេះនឹងកាលនឹងបងបានទៅយកដើមជំឡូងនឹងយកវាមកកាច់ហើយដាក់វាប្រក់ពីលើធ្វើជាជំរក។

ក៖ ហើយយើចូលទៅអង្គុយទៅ?

ខ៖
នឹងហើយពេលខ្លះនឹងបងបានយកក្រមាយើងនឹងទៅចង់វាដើម្បីអោយមានម្លប់ខ្លះទៅព្រោះវាក្ដៅណាស់កាលនឹងនោះវាគ្មានម្លប់ដើមឈើធំនោះទេព្រោះនៅទៅនោះសុទ្ធតែចំការជំឡូងនឹង
ហើយបងកាលនឹងបងមានដាក់ជាផ្ទាំងសំរាប់ដាក់បាំងកំដៅថ្ងៃនឹងកុំអោយនៅហាលក្ដៅខ្លាំងពេកវាមិនសូវស្រួលទៀតនឹងពេលដែលនៅហាលថ្ងៃនឹងម្ដងៗនោះ។

ក៖
ចាសហើយចឹងពេលដែលបងបានមកធ្វើការនោះភ្នំពេញវិញដោយសារតែនៅទៅនោះវាពិបា

កចឹងហើយពេលដែលមកបានមកធ្វើការនៅភ្នំពេញហើយនឹងតើបងបានទៅធ្វើការនៅឯណាទៀតដែលឬទេ?

ខ៖

អត់ទេអូ!!ប៉ុន្តែពេលដែលបងបានចេញពីស្រុកលើនឹងបងបានទៅធ្វើការនៅឯចំការម្រិចទៅស៊ីឈ្នួលប៉េះម្រិចម្តង។

ក៖ ហើយនៅឯណាដែលបងចំការម្រិចនឹង?

ខ៖ នៅខាងស្រុកលើនឹងដែលនឹងអូន។

ក៖ ចាសចឹងកាលនឹងបងបានប៉េះបានក្នុងមួយថ្ងៃបានប៉ុន្មានដែរបង?

ខ៖ កាលនឹងបងប៉េះបានក្នុង១ថ្ងៃជាធម្មតាបាន១៥០០០រទេ។

ក៖ អូ!! ចឹងតើតំលៃនេះជាទូរទៅគេប៉េះបានប៉ុណ្ណឹងឬក៏ជាតំលៃដែលបានថ្ងៃ?

ខ៖

តំលៃម្រិចក្នុង១គីឡូបានតែ៨០០រទៅ៦០០រទេក្នុង១គីឡូលុយខ្មែរយើងនឹងហើយវានឹងនៅខ្សត់គេនឹងយើងប៉េះបានមិស្វូវច្រើនទេ...

ក៖ ចឹងក្នុង១ថ្ងៃបងអាចប៉េះបានប៉ុន្មានគីឡូដែល?

ខ៖ ក្នុងមួយថ្ងៃចឹងទៅតែម្នាក់ឯងនឹងបងអាចប៉េះបាន២០កគីឡូអីចឹងដែរ។

ក៖ អូ!!ចឹងឃើញលុយបាត់ហើយចឹងនោះ។

ខ៖

ហាហតាមពិតទៅបងប៉េះនឹងនៅចាញ់គេទេគេប៉េះបានច្រើនជាងបងណាអូនព្រោះគេនឹងបានធ្វើមុនបងហើយគេជាបុគ្គលិកចាស់ចឹងទៅណាអូន។ហើយគេខ្លះទៅក្នុង១ថ្ងៃអីចឹងទៅគេអោយប៉េះបាន៣០គីឡូងទៅ៥០គីឡូងអីណំ ចឹងណាអូន។

ក៖ ចាសចឹងកាលនឹងមូលហេតុអ្វីបានជាបងសំរេចចិត្តដើម្បីឈប់ធ្វើការងារមួយនឹង?

ខ៖ ហឺ...

ក៖ មូលហេតុអ្វីបានជាបងសំរេចចិត្តដើម្បីឈប់ធ្វើការនៅឯចំការម្រិចនឹងនោះ?

ខ៖
អូដោយសារតែបងតស៊ូមិនរួចចឹងហើយបានជាបងនឹងគិតថាខ្លាចតែបងខំទៅបងនឹងឈឺហើយពេលដែលបងឈឺនឹងតើបងមានលុយមកឯណាដើម្បីមើលជំងឺរបស់ខ្លួននោះចឹងហើយបានជាបងដឹងថាបងត្រូវឈប់ធ្វើការងារនឹងហើយត្រូវមករកការងារធ្វើនៅឯទីក្រុងភ្នំពេញវិញបានជាវាមើលទៅរាងធូជាងនៅឯស្រុកលើនឹង
ហើយគិតមើលការនឹងបងដឹងថាអោយតែស្មាលនឹងឡើងនឹងវាកំពុងតែក្តៅហើយនេះដូចជាម៉ោងប្រហែល២ឬជិត២អីនឹងកំពុងតែក្តៅខ្លាំងហើយបងទ្រាំមិនបាននោះទេ
ហើយបងធ្វើការងារនឹងបងត្រូវចាប់ផ្តើមពេលថ្ងៃនឹងនៅម៉ោង១រហូតដល់ម៉ោង៤នៅម៉ោង៤នឹងគេចាប់ផ្តើមសារវាហើយ
ហើយពេលនឹងណាបងនឹងខំធ្វើការងារហើយដើរបងនឹងប៉េះវាភ្នែកខំប្រឹងសំលឹងរកមើលដូចជាចោរអីចឹងដែរនឹងកាលនឹង។

ក៖ ចាសព្រោះចាប់ចោលហើយទៅមួយទៀតយ៉ាងលឿន។

ខ៖ អើ បើត្រូវមើលថាផ្លែនឹងត្រូវចាស់ហើយបងត្រូវប្រយត្ន័មិនអោយជុះស្លឹកដើមម្រិចគេទេ បើគេឃើញនឹងគេនឹងស្តីអោយយើងហើយអូនអើយ
ជ្រុះផ្កានិងទងម្រិចរបស់គេនឹងក៏មិនបានដែលហើយភ្នែកបងនឹងត្រូវមើលចឹងទៅណា។
មើលទៅថាតើអានឹងវាចាស់យើងត្រូវប៉េះហើយបើវាមាននៅខ្ចីអីនឹងយើងត្រូវទុកវាសិនហើយកាលនឹងយើងមិនទៅប៉េះរាងមួយៗនោះទេកាលនឹងត្រូវប៉េះឡើងមើលទៅម៉ាត់ៗចឹងទៅ។

ក៖ ចាសហើយពេលដែលបងបានធ្វើការនៅទៅនោះតើថៅកែនឹងគាត់ជាជនជាតិខ្មែរតើបង?

ខ៖ ចាសគាត់ជាខ្មែរយើងទេ។

ក៖
ហើយកាលនឹងតើគាត់មានអោយអ្វីសំរាប់អោយបងសំរាប់ជាការលើទឹកចិត្តនៅក្នុងការងារដែលឬទេបង?

ខ៖ ការនឹងគាត់មានបានអោយទឹកក្រូចអោយបងដែលនឹង
ល្ងាចឡើងមានទឹកក្រូចហើយកាលនឹងមាននេះអីច្រើនបើមនុស្សឡើង៣០ទៅ៥០នាក់ហើយ
នឹងតែគេនៅតែមានអោយយើងបានផឹកទឹកក្រូចជុំគ្នាអីចឹងទៅណា។
ចំណែកឯនៅឯស្រុកលើនឹងខែនេះអីចឹងវារាងខ្សត់បន្លែហើយព្រោះតែវារាងគ្រៀមអស់ហើយ
ព្រោះបើជាខែវស្សាវិញយើងមានជាបន្លែអីខ្លះសំរាប់អោយយើងប៉េះស្លដែលនឹង។

គ៖ ឯងនិយាយចឹងធ្វើអីឯងនិយាយអីដែលវាសំខាន់ៗទៅណា។

ខ៖ អើ
‼កាលនឹងពេលខ្លះទៅបងនឹងខំធ្វើការងារពេកអីនឹងជួនកាលនឹងដើបមុខឡើងអីនឹងស្រាប់តែ
ងងិតមុខ
ហើយអូនអើយកាលនឹងណាដែបងនឹងភ្នែករបស់បងនឹងមិនបានឈប់សំរាកទេពេលដែលកំពុ
ងធ្វើការនោះគឺខំប្រឹងប៉េះលឿនៗ
សំលឹងរកវាចឹងៗរហូតមិនស្រួលនោះទេសំលឹងវារហូតនឹងទំរាំបាន១ទៅ២គីឡូអីនឹងហើយវា
មានជ្រុះស្លឹកទងដើមម្រិចអីនឹងគេស្ដីអោយយើង
ពិបាកណាស់អូនអើយយើងទៅស៊ីឈ្នួលគេនឹងហ៎តែយើងមកឯភ្នំពេញនឹងហើយមានគេស្ដី
អោយយើងដែលមែនតែយើងដឹងថាយើងមានសុវត្ថិភាពយើងដេកទៅមិនខ្លាចភ្លៀងហើយមិន
ខ្លាចផ្គូឡន់អើហើយមានពស់ចឹងហើយងងឹងមុខអីនឹងដែលធ្វើអោយយើងបារម្ភ។

ក៖
ចុះចំណែកឯបងធ្វើការងារនឹងបងមានបានជួបការលំបាកឬមានគ្រោះថ្នាក់អីទេដូចជាពស់ល់
ជីកអី?

ខ៖ អត់មានប្រទះទេអូនប៉ុន្ដែបងបានធ្លាក់ពីលើជ្រលងម្រិច
បងបានធ្លាប់ធ្លាក់ពីលើជ្រលងម្រិចចឹងទៅហើយខាតយើងខាតព្រោះពេលដែលយើងនឹងឈឺ
នឹងយើងមិនបានទៅធ្វើការងារអី។

គ៖ អត់លុយទៀត។

ខ៖ អត់លុយទៀត។

កៈ
ចាសចឹងកាលនឹងបងដូចថាថ្លៃពេទ្យអីនឹងតើថៅកែលគេជាអ្នកចេញលុយអោយឬក៏បងត្រូវចេញលុយខ្លួនឯង?

ខៈ
យើងខ្លួនឯងមិនមែនថៅកែលទេព្រោះមកពីយើងនឹងមិនបានប្រយ័ត្នខ្លួនឯងចឹងយើងត្រូវចេញលុយបង់អោយថ្លៃការព្យាបាលដោយខ្លួនឯង។

កៈ អឺ!!

ខៈ
ចឹងយើងនឹងត្រូវតែយកលុយខ្លួនឯហើយមើលថែខ្លួនឯងខាតតែខ្លួនយើងទៀតនឹងគ្មានបានអីទេគ្មានអីយើងតែខ្លួនឯង ពេលដែលយើងមានជំងឺ
ឈឺរងារអីចឹងណាហើយពេលនឹងយើងគ្មានបានធ្វើការហើយគ្មានលុយទេហើយយើងនឹងត្រូវចំណាយលុយនឹងទៅទិញអីសំរាប់ហូបទៀតចឹងណាលុយរហូតនឹង។ហើយកាលនឹងបើបងមានក្នុងថ្ងៃ៥០០០រចឹងបងញ៉ាំតែបង្អែមអីតិចតួចទៅអស់តែ១០០០រអីចឹងទៅហើយនៅប៉ុន្មានអីនឹងបងខំសន្សំសន្វៃវា។

កៈ ហើយកាលនឹងបងបានធ្លាក់ពីលើជ្រលងភ្នំនឹងបងបានត្រូវកន្លែងណាខ្លះដែល?

ខៈ នេះដូចជាមាននៅចង្កេះអីនឹងបងមានថ្លោះចង្កេះអីចឹងទៅណាអានឹងណា។

កៈ ហើយឥឡូវនឹងបងបានជាហើយ?

ខៈ បងបានជាហើយ។

កៈ ជាបាត់ឈឺងតែម្តងមិនមានការរើលឡើងវិញទេ?

ខៈ
ជាដែលប៉ុន្តែដូចថាយើងឥឡូវនឹងវារាងចាស់ដែលចឹងវាមានទៅឈឺអីផ្សេងទៀតចឹងដែលចឹងណា។

កៈ ចាសចឹងរាល់ថ្ងៃនឹងបងមានឈឺជំងឺអីខ្លះដែលបង?

ខ៖ បងមានឈឺជឺងឺជង្គុញនឹងហើមជើងនឹងណាឥឡូវនឹងក៏នៅហើមមិនទាន់បានបាត់ដែល។

ក៖
ហើយពេទ្យគេថាយ៉ាងម៉េចដែលតើបងមានបានទៅមន្ទីពេទ្យសំរាប់អោយគាត់ពិនិត្យមើលដែលឬទេ?

ខ៖ បងមិនបានហ៊ានទៅជួបនឹងពេទ្យផងនឹង។

ក៖ ម៉េចចឹងបង?

ខ៖
បងខ្លាចថាពេទ្យថាឈឺអីៗចឹងទៅខ្ញុំនឹងវាភ័យព្រោះតែបងនឹងវាគ្មានលុយសំរាប់នឹងព្យាបាលជំងឺនឹងនោះទេអូន បើពេទ្យគេថាបងនឹងកើតជំងឺទឹកនោមផ្អែមអីនឹងបងយ៉ាប់ទៀតមិនខាតទេហើយទៅលើសដើមទៀតហើយចឹងទៅបងនឹងវាភ័យមួយទៀតនឹងបើពេទ្យគេថាបងនឹងកើតជំងឺទឹកនោមផ្អែមដែលនឹងបងប្រាប់ទៅដឹងថាយ៉ាបជាមិនខាតឡើយ។

ក៖ ម៉េចចឹងបងតើបងមានរោគសញ្ញាម៉េចដែរខ្លះ?

ខ៖
កាលពីមុននឹងបងចេះតែឈឺដោះហើយដល់ពេលដែលបងទៅពេទ្យអីចឹងទៅគេថាបងនឹងវាមានជំងឺរលាកទឹកដោះចឹងទៅណា
ហើយយើងបានទៅមើលពេទ្យច្រើនដែលនឹងហើយគេថាយើងនឹងវារលាកគេបានអោយថ្នាំយើងលេបទៅចឹងបងបានជាហើយ។

ក៖ ចឹងហ៎បងចាស
ចាសចឹងតាមបងបាននិយាយមកនឹងបងបានធ្វើការច្រើនដែរចឹងបងពិតជាមានបទពិសោធន៍ជីវិតរបស់បងច្រើនដែលហើយចឹងតើនៅក្នុងជីវិតរបស់បងនៅពីមុនរហូតដល់ឥឡូវនឹងតើវាបានបង្រៀនអ្វីខ្លះដល់បង?

ខ៖
វាបានបង្រៀនប្រាប់ថាត្រូវតែខំប្រឹងធ្វើការងារប៉ុន្តែត្រូវគិតពីសុខភាពរបស់យើងដែលព្រោះយើងមិនមែនមានសុខភាពល្អរហូតនោះទេព្រោះទៅវាមានក្តៅនឹងត្រជាក់ចឹងដែលនឹង។

កៈ ចាសហើយបងមានបទពិសោធន៍ល្អៗនៅក្នុងជីវិតរបស់បងដែរឬទេ?

ខៈ
ជីវិតវាលំបាកអីចឹងកូនទុកចោលចឹងហើយគ្មានអ្នកនរណាមើលហើយប្តីអីនឹងក៏គាត់មិនគិតចឹងហើយវាលំបាកគ្មានអីល្អនោះទេ
ពេលដែលនៅជាមួយនឹងម៉ែឪនឹងក៏មានប្រវត្តិពិបាកចឹងហើយជីវិតរបស់បងមើលទៅវាគ្មានអីដែលល្អទេកូនអើយ។

កៈ
ចាសហើយចុះបងមានបទពិសោធន៍បានជួបរឿងអីមួយនៅក្នុងជីវិតរបស់បងហើយបងនឹងឃើញវាហើយធ្វើអោយបងសប្បាយចិត្តនោះទេ?

ខៈ អត់មានទេអូន។

កៈ
ចឹងអរគុណបងច្រើនដែលបានចំណាយពេលវេលាសំរាប់អោយខ្ញុំសំភាសន៍នៅថ្ងៃនេះចឹងបងមានពាក្យពេជ្រអ្វីជាចុងក្រោយ?

ខៈ
បងថាសុំអោយខាងសាលាជួយដល់ប្រជាជននៅស្រុកខ្មែរយើងព្រោះប្រជាជននៅក្នុងស្រុកខ្មែរយើងនឹងរឹតតែខ្សត់ទៅខ្សត់ហើយចង់អោយខាងសាលានៅឯស្រុកខ្មែរយើងនឹងមិនថាតែបងនោះទេអ្នកណាៗក៏ដោយព្រោះសព្វថ្ងៃនឹងការងារអីក៏មិនសូវមានធ្វើដែលហើយសម្បីតែរោងចក្រក៏បានបិទទ្វារបន្តើរដែលនឹងចឹងហើយបានជាបងសុំសំណូមពរអោយខាងសាលានឹងជួយដល់ប្រជាជនខ្មែរយើងចឹងថាអោយមានការងារធ្វើគ្រាប់កន្លែងចឹងទៅណាព្រោះវាឥឡូវចេះតែដុនដាបៗទៅចឹងណាហើយបងសំភាសន៍នឹងគ្មានចង់បានអីនោះទេបងចឹងអោយតែជួយដល់ប្រជាជនខ្មែរយើងផងព្រោះមើលទៅវាវេទនាណា។

កៈ ចឹងបងមានគំរោងអី?ហើយបើបងចង់ធ្វើការបងចង់ធ្វើផ្នែកអ្វីដែរ?

ខ៖ បើបងចង់ធ្វើបងចង់ធ្វើជាអ្នកអនាម័យអីនឹងណាអូន ព្រោះមានតែចឹងព្រោះបើធ្វើការនៅរោងចក្រអីនឹងគេបិទទ្វារអស់ហើយនឹងតើមានការងារណាធ្វើទៅ ទៅអស់ហើយគ្មានទេទៅអស់ហើយ។មែនទេបង?

គ៖ នឹងហើយ.....

ខ៖ របស់វាថ្លៃហើយរបស់វាមានជាតិគីមីទៀតចឹងគ្មានអីទេសព្វថ្ងៃនឹងនោះចង់អោយតែសាលានឹងគេបានជួយទៅកុំអោយបន្លែអីនឹងមានជាតិគីមីច្រើនពេក។

ក៖ ចាស ចឹងតើបងមានបានស្លាប់ដំណឹងជ្រើសរើសអីដែលពេលខ្លះគេប្រើអោយដឹងតាមរយៈវិទ្យុផ្សេងៗអីដែលនៅក្នុងទីក្រុងភ្នំពេញណាបង?

ខ៖ មានអូនប៉ុន្តែវាពិបាកណាស់ព្រោះកាលនឹងបងបានដាក់ប៉ុន្តែដាក់ពាក្យចូលធ្វើការដែលប៉ុន្តែហើយទៅវាឡើងរាប់ខែរាប់ថ្ងៃដែលបានគេហៅយើងទៅធ្វើតេសបានចូលធ្វើការងារនឹងនោះគេជ្រើសរើសរកតែអ្នកដែលចេះនោះទេហើយអ្នកដែលមិនចេះនឹងគេមិនយកទៅធ្វើការនោះទេជាក់ស្តែងដូចជាបងដែលបងមិនបានមានជំនាញអីសំរាប់ធ្វើការងារអោយគេបានទេដូចនេះហើយទៅបានជាបងពិបាកក្នុងការរកការងារធ្វើនឹងណាអូនអើយវាមិនស្រួលរកទេការងារមួយនោះវារកបានហើយបងបានយក cvដាក់អោយគេហើយនឹងតែគេមិនទាន់នឹងហៅយើងទៅផងវាយូរហើយឡើង៥ខែហើយនេះដែលបងបានដាក់ការងារមួយដើម្បីនឹងចូលទៅធ្វើការងារនឹងគេដែលតែគេមិនទាន់ទាក់ទងមកបងផងនឹងអូនអើយយ៉ាប់ណាស់បងមិនដឹងជាត្រូវទៅណាមកនៃហើយធ្វើការងារអ្វីទៀតទេដល់ពេលចឹងទៅនោះចឹងបានថាបើឥឡូវនឹងគ្មានការងារអីសំរាប់ធ្វើទេហើយនិយាយពីcvនិងបងបានតែដាក់ចោលរហូតនឹងតែមិនលឺដំណឹងអីសោះឥឡូវនឹងហើយចឹងបងនៅតែផ្ទះនឹងសព្វថ្ងៃនេះគ្មានទៅណាទេបងបានដាក់ទៅ២ទៅ៣កន្លែងហើយៗនឹងចឹងណាអូនវាចឹងឯង។

ក៖ តើបងរំពឹងប្រាក់ខែប៉ុន្មានដែលបង?

ខ៖ ប្រាក់ខែហឺ
បងយើងវាអស់ហើយត្រឹម១២០$ទៅ១៣០$ឬ១៥០$ទៅ១៦០$អីនឹងសំរាប់បងវាសមរម្យហើយហើយប្រជាជនខ្មែរយើងឥឡូវនឹងភាគច្រើនគេបានតែប៉ុណ្ណឹងដែលនឹងវាចឹងឥឡូវវាមិនមានទេខ្លះទៅវាបានត្រឹមតែ១៣០អីវាអស់មិនលើសនឹងទៀតទេមើលទៅនោះ។

ក៖
ចាសដូចថាការងារខាងសំអាតអីនឹងពេលដែលបងចូលទៅមានគេបង្រៀនបងបន្ថែមទៀតហើយចឹងពេលដែលបងចូលទៅធ្វើការងារគ្រាន់តែចំណាយកំលាំងនឹងតាំងចិត្តធ្វើព្រោះខាងនឹងគេមិនសូវជាត្រូវការជំនាញវិជ្ជាច្រើននោះទេពេលហើយមួយទៀតនឹងខាងប្រភេទការងារនឹងគេត្រូវតំរូវអោយយើងនឹងមានការតស៊ូ...

ខ៖ ហឺ!!

ក៖
ចឹងដូចបងផ្ទាល់ចឹងបើមានឪកាសការងារដែលខ្ញុំបានដឹងខ្ញុំនឹងអាចទាក់ទង់មកបងបានតាមរយ:ខាងក្រៅ។

ខ៖ ចាស

ក៖
ចាសហើយនេះវាមិនមែនជាគំរោងរបស់សាលាទេសូមបញ្ជាក់គំរោងរបស់សាលាគេគ្រាន់តែចង់បានពត៍មានរបស់ប្រជាជនកម្ពុជាដែលពួកគាត់មានប្រវត្តិដ៏អស្ចារ្យរបស់ហើយពួកបានចែករំលែកនូវប្រវត្តិនឹងបទពិសោធន៍របស់គាត់នៅពេលដែលមានការសំភាសន៍
ហើយចឹងខាងសាលាគេនឹងយកសំលេងដែលសំភាសន៍ហើយនឹងទៅចង់ក្រដាងសារគេយកទៅដាក់នៅក្នុងវេបសាយរបស់សាលាអោយអ្នកជំនាន់ក្រោយគេបានស្តាប់រឺអ្នកដែលគាត់មានការប្រើប្រាស់អ៊ីនធឺណែតនឹងចូលទៅកាន់គេហ:ទំព័រwww.byu.cambodia oriel history.com
ហើយគេនឹងអាចរកឃើញសំលេងរបស់បងបានតាមរយ:នឹងមានជារូបផតរបស់បងស្រីផ្ទាល់តែម្តងហើយសព្វថ្ងៃនេះខាងគំរោងរបស់សាលាមួយនេះយើងមានចំនួនអ្នកដែលយើងបានសំភាសន៍នឹងប្រើនាក់ដែលចឹងពេលដែលបងទំនេរឬបងចង់ឃើញនឹងស្តាប់លឺសំលេងរបស់បងម្តងទៀតនឹងបងអាចប្រើអ៊ីនធឺណែតហើយចូលទៅកាន់គេហ:ទំព័រដែលខ្ញុំបានប្រាប់បងខាង

លើហើយមួយវិញទៀតចំពោះការសំណូមពររបស់បងស្រីផ្ទាល់ខ្ញុំនឹងប្រាប់បងស្រីខាងក្រៅពេលដែលខ្ញុំបានដឹងថាមានឱកាសការងារដែលសាកសមនឹងបងស្រីហើយបងអាចធ្វើបានឬបងចាប់អារម្មណ៍ចង់ធ្វើការងារមួយនឹងអីបងអាចទំនាក់ទំនងទៅដោយខ្លួនឯងបានព្រោះខ្ញុំបានដឹងពីពត៍មានដែលគេបានផ្សព្វផ្សាយមួយចំនួនណាបង..

ខ៖ ចាស ចាស!!

ក៖ ចាសបងចឹងជាចុងក្រោយបងមានពាក្យពេជ្រអ្វីដែរឬទេបង?

ខ៖ បងអត់មានពាក្យពេជ្រអ្វីទេ....

ក៖
តើបងមានពាក្រសំរាប់ផ្តាំនឹងទុកអោយអ្នកដែលគេបានស្តាប់សំលេងរបស់បងស្រីនៅថ្ងៃនឹងជាពិសេសដល់អ្នកជំនាន់ក្រោយបងដែលទាក់ទងទៅនឹងបងពិសោធន៍ជីវិតពិតរបស់បងដែលបងធ្លាប់បានឆ្លងកាត់?

ខ៖
បងមានអីច្រើននោះទេបងគ្រាន់តែចង់អោយប្រជាជនស្រុកខ្មែរយើងនឹងក្រោកឈរឡើងព្រោះប្រជាជនស្រុកខ្មែរយើងនឹងចេះតែដុនដាបទៅហើយបងអត់មានអីទៀតទេបងមានតែពាក្យពេជ្រប៉ុណ្ណឹងឯងដើម្បីផ្តែផ្តាំដល់ប្រជាជនស្រុកខ្មែរយើងនឹង។(
អូនអើយបងឈឺចង្កេះណាស់អូន)

ក៖ ចាសអរគុណបងសូមជំរាបលាបង។(ចាំខ្ញុំជួយលើកបង..)